**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខ:016 សជណ/កសស/កជន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុងព្រះសីហនុ, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥

# សេចក្តីជូនដំណឹង

## " ស្តីពីការអនុវត្តយកថ្លៃឈ្នួលសេវាកម្មទំនិញជាស៊ីម៉ង់ត៍ "

ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានកិត្តិយសសូមជំរាបជូនបណ្តាអតិថិជនម្ចាស់នាវាដឹកជញ្ជូនទំនិញស៊ីម៉ងត៍ទាំងអស់ជ្រាបថា ក្រោយពីបានការអនុម័តពីអង្គប្រជុំក្រុមប្រឹក្សាភិបាល ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៥ និងបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ កសស បានកំណត់នូវវិធានការណ៍ថ្មីសំរាប់ទំនិញជាស៊ីម៉ងត៍ឆ្លងកាត់ កសស ដូចខាងក្រោមនេះ

១-កសស យកតែថ្លៃពន្ធនាវា (Port Dues)ប៉ុណ្ណោះគឺ **0.80US$/GRT** ។

២-ការលើកដាក់និងផ្ទេរផ្ទុកគឺប្រគល់សិទ្ធឱ្យម្ចាស់ទំនិញជ្រើសរើសៈ

ក-អាចប្រើប្រាស់កំលាំងកម្មករនិងគ្រឿងចក្ររបស់ខ្លួនផ្ទាល់

ខ-អាចជួលគ្រឿងចក្រឬកម្មករ កសស តាមតំលៃដូចខាងក្រោមៈ

ថ្លៃផ្ទេរស៊ីម៉ងត៍ ដាក់រថយន្ត ដោយប្រើកម្មករនិងគ្រឿងចក្រ កសស

-ស៊ីម៉ងត៍ជា**JumboBags**គិត **0.50US$**/តោន(រួមមានកម្មករនិងរថយន្តស្ទូច)

-ស៊ីម៉ងត៍ជាបាវ គិត **0.90US$**/តោន(រួមមានកម្មករ-មធ្យោបាយលើកដាក់-អ្នកបើកដងយោង)

៣-កសស ពុំមានអ្នកកត់ត្រានៅក្រោមដងយោងនាវាទេគឺម្ចាស់ទំនិញទទួលផ្ទាល់ពីនាវា ឬពីតំណាងនាវា ។

សេចក្តីជូនដំណឹងដែលមានពីមុនផ្ទុយនឹងសេចក្តីជូនដំណឹងថ្មីនេះត្រូវចាត់ទុកជាមោឃៈ ។

អាស្រ័យដូចបានជំរាបជូនដំណឹងខាងលើ សូមបណ្តាអតិថិជននិងក្រុមហ៊ុននាវាទាំងអស់មេត្តាជ្រាបចូលរួមសហការតាមការគួរ ។/.

**ប្រធានអគ្គនាយក**

លូ_គឹមឈន់

វិថីផែ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ទូរសព្ទ័លេខ : (៨៥៥) ៣៤ ៣៨០ ៤៥០ ទូរសារលេខ: (៨៥៥) ៣៤ ៩៣៣ ៦៩៣